01148481

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2015
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Samm Rada

ឯកសារ C2/4

ការចោទប្រកាន់ព្រហ្មទណ្ឌ និងការចោទប្រកាន់អង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៣)

ចំពោះមុខ៖
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Steven J. BWANA
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥

---

សាធារណៈ

**សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន**

---

**មេធាវីរបស់ មាស មុត៖**
មេធាវី អាង ឧត្តម
មេធាវី Michael KARNAVAS

**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**
មេធាវី ជេត វណ្ណលី
មេធាវី ហុង គីមសួន
មេធាវី គីម ម៉េងឃី
មេធាវី ឡោ ជុនធី
មេធាវី សំ សុគង់
មេធាវី Ferdinand DJAMMEN-NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Martine JACQUIN

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៣)

ឯកសារ C2/4

| | |
|---|---|
| មេធាវី ស៊ិន សុវ៉ន | មេធាវី Emmanuel JACOMY |
| មេធាវី ទី ស្រ៊ីនណា | មេធាវី Christine MARTINEAU |
| មេធាវី វ៉េន ពៅ | មេធាវី Barnabe NEKUI |
| មេធាវី Laure DESFORGES | មេធាវី Lyma NGUYEN |
| មេធាវី Herve DIAKIESE | មេធាវី Beini YE |

01148483

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៣)

ឯកសារ C2/4

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលសំណើបន្ទាន់របស់ មាស មុត នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន")[1]។

## I- នីតិវិធី

១. នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ និងបានជូនដំណឹងអំពីបទចោទប្រឆាំងនឹង មាស មុត តាមរយៈមេធាវីរបស់គាត់ ("ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ")[2]។ ដីកាសម្រេចនេះ ត្រូវបានចេញ បន្ទាប់ពីនីតិវិធីដែលផ្តួចផ្តើមដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សំដៅធានាថា មាស មុត មានវត្តមាន ពេលកោះឱ្យមកបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤។ ប៉ុន្តែ មាស មុត មិនបានមកបង្ហាញខ្លួននោះទេ[3]។

២. នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ មេធាវីរបស់ មាស មុត (ឬ"មេធាវីការពារក្តី") បានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ("បណ្តឹងឧទ្ធរណ៍") នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលមាន ៦១ ទំព័រ និងដាក់តែជាភាសាអង់គ្លេស មេធាវីការពារក្តីបានស្នើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រ ដែលកំណត់ដោយសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក និងស្នើសុំការអនុញ្ញាតដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសសិន

---

[1] ឯកសារ C2/2។ សំណើនេះត្រូវបានជូនដំណឹង នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ម៉ោង ៤ និង ៣៣ នាទី រសៀល។ ដូច្នេះ រយៈពេលកំណត់ក្នុងការឆ្លើយតបចាប់ផ្តើមគិតចាប់ពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥។

[2] ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128, ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128.1។

[3] ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66, កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D122 (នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្តី មាស មុត បានចូលមក[illegible] ចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប៉ុន្តែ មាស មុត អវត្តមាន), សេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តី[illegible]របស់ មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1, សេចក្តីជូនដំណឹងស្តីពីការ[illegible] ដីកាកោះ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1.1, ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ C1

ហើយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយ។ ដោយសារ នៅពេលនោះ អង្គបុរេជំនុំជម្រះមិនទាន់មានក្រុមប្រឹក្សាជំនុំជម្រះនៅឡើយ សំណើរបស់មេធាវីការពារក្តីមិនអាចត្រូវបានពិចារណានៅមុនថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥ បានឡើយ។ នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់មេធាវីការពារក្តីថា សំណើសុំបន្ថែមចំនួនទំព័រមិនអាចត្រូវបានពិនិត្យទេ ដោយសារតែសំណើនេះត្រូវបានធ្វើឡើង នៅក្នុងបណ្តឹងសាទុក្ខផ្ទាល់ ហើយបានស្នើឱ្យមេធាវីការពារក្តីដាក់សំណើដាច់ដោយឡែកមួយ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥[4]។ មេធាវីការពារក្តីបានដាក់សំណើរបស់ខ្លួន នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ("សំណើសុំបន្ថែមចំនួនទំព័រ")[5]។

៣. នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឱ្យនគរបាលយុត្តិធម៌នាំ មាស មុត មកបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់សវនាការតទល់គ្នា ដើម្បីពិចារណាចេញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន អនុលោមតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង ("ដីកាបង្គាប់ឱ្យនាំខ្លួន")[6]។

៤. នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដោយបានស្នើសុំអង្គបុរេជំនុំជម្រះបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន រហូតទាល់តែអង្គបុរេជំនុំជម្រះសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងបណ្តឹងឧទ្ធរណ៍ ជាមុនសិន[7]។

៥. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះបានបដិសេធសំណើសុំបន្ថែមចំនួនទំព័រ[8]។

---

[4] អ៊ីមែលរបស់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះផ្ញើជូនមេធាវីការពារក្តី នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥។

[5] សំណើរបស់ មាស មុត សុំបន្ថែមចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ D128/1/1។

[6] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2។

[7] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន សេចក្តីសន្និដ្ឋាន។

[8] សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំបន្ថែមចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍លើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ១០ ខែ មិថុនា ២០១៥ *សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន*

ដើម្បីជៀសវាងកុំឱ្យមេធាវីការពារក្តីទទួលរងនូវព្យសនកម្មពីការបដិសេធនេះ អង្គបុរេជំនុំជម្រះបានពន្យារពេលដាក់បណ្តឹងឧទ្ធរណ៍ រហូតដល់ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។ មេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥[9]។

៦. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ហើយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធសំណើនេះដោយហេតុថា សំណើនេះមិនអាចទទួលយកបាន និងគ្មានមូលដ្ឋាន (“ចម្លើយតប”)[10]។

៧. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចម្លើយតបនេះ និងដកចម្លើយតបនេះចេញពីសំណុំរឿង ហើយឯកភាពដោយមិនបង្អង់ តាមសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន (“សារណាតប”)[11]។

## II- ឧទ្ទិករណ៍របស់ភាគី

៨. ជាបឋម មេធាវីការពារក្តីបានលើកឡើងថា អង្គបុរេជំនុំជម្រះមានយុត្តាធិការក្នុងការបង្គាប់ឱ្យផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន អនុលោមតាម “ការបកស្រាយទូលំទូលាយនូវវិធាន ២១ នៃវិធាន

---

ឯកសារ D128/1/2។

[9] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ D128/1/3។

[10] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2/2។

[11] សារណាតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2/3។

ផ្ទៃក្នុង” ដោយសារសេចក្តីសម្រេចលើបញ្ហានេះមានភាពចាំបាច់ ដើម្បីធានាបាននូវភាពយុត្តិធម៌នៃនីតិវិធី នៅក្នុងដំណាក់កាលស៊ើបសួរ[12]។ ចំពោះសារធាតុ មេធាវីការពារក្តីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចបន្តនីតិវិធីស៊ើបសួរប្រឆាំងនឹង មាស មុត និងមិនអាចមានបំណងឃុំខ្លួន មាស មុត បណ្តោះអាសន្ន បានឡើយ នៅខណៈដែលមេធាវីការពារក្តីកំពុងជំទាស់នឹងនីត្យានុកូលភាពនៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ[13]។ ក្រៅពីនេះទៀត មេធាវីការពារក្តីបានបញ្ជាក់ថា ការការចាប់ខ្លួន និងការឃុំខ្លួន មាស មុត អនុលោមតាមដីកាបង្គាប់ឱ្យនាំខ្លួន នៅខណៈដែលដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ កំពុងត្រូវបានជំទាស់ គឺជា “ឆាកល្ខោនបោកបញ្ឆោត” និងជាការរំលោភលើសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានសេរីភាព និងការជំនុំជម្រះក្តីដោយយុត្តិធម៌[14]។

៩. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចទទួលយកបាន ដោយហេតុថាសំណើនេះមិនស្ថិតនៅក្រោមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ។ ចំពោះការយោងលើវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលមេធាវីការពារក្តីយកមកធ្វើជាមូលដ្ឋាននៃសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា វិធាន ២១ មិនមែនជាប្រភពតែមួយមុខដែលផ្តល់យុត្តាធិការដល់អង្គបុរេជំនុំជម្រះនោះឡើយ[15]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានបញ្ជាក់ផងដែរថា មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃកាលៈទេសៈពិសេស ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើអន្តរាគមន៍ ដើម្បីរក្សាភាពយុត្តិធម៌នៃនីតិវិធីឡើយ ជាពិសេស មេធាវីការពារក្តីគួរតែអាចដាក់សំណើរបស់ខ្លួនទៅសហចៅក្រមស៊ើបអង្កេត[16]។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា សំណើនេះមិនស្ថិតនៅក្នុងយុត្តាធិការជាប់មកជាមួយរបស់អង្គបុរេជំនុំជម្រះនោះទេ ដោយសារថាការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនមិនអាចរាំងស្ទះដល់នីតិវិធីបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ហើយនីតិវិធីបណ្តឹងឧទ្ធរណ៍

---

[12] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន កថាខណ្ឌ ៨។

[13] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន កថាខណ្ឌ ៩-១០។

[14] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន សេចក្តីផ្តើម និងកថាខណ្ឌ ១០-១១។

[15] ចម្លើយតប កថាខណ្ឌ ១១។

[16] ចម្លើយតប កថាខណ្ឌ ១០ និងកថាខណ្ឌ ១២-១៣។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

មិនពាក់ព័ន្ធនឹងដីកាបង្គាប់ឲ្យនាំខ្លួនទាល់តែសោះ[17]។ ចំពោះសារធាតុ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ការផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនមិនផ្ទុយនឹងគោលការណ៍ ដែលចែងថាការស៊ើបសួរនៅតែបន្ត ក្នុងពេលមានបណ្ដឹងឧទ្ធរណ៍[18]។ ព្រះរាជអាជ្ញាអន្តរជាតិក៏បានអះអាងផងដែរថា មាស មុត មិនបានរកឲ្យឃើញថា ហេតុអ្វីបានជាការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន អាចនឹងរំលោភលើសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[19] និងសិទ្ធិក្នុងការទទួលបានសេរីភាព[20]។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានចេញយ៉ាងត្រឹមត្រូវ ហើយមូលហេតុដែល មាស មុត អាចត្រូវចាប់ខ្លួន ត្រូវបានបញ្ជាក់ជូនគាត់យ៉ាងច្បាស់ និងថា ការសម្រេចណាមួយដើម្បីឃុំខ្លួន មាស មុត បណ្ដោះអាសន្ន អាចធ្វើឡើងបាន ក្រោយពេលមានសវនាការតទល់គ្នា[21]។

១០. មេធាវីការពារក្តីបានឆ្លើយតបវិញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនជាប់ពាក់ព័ន្ធអ្វីនឹងដីកាបង្គាប់ឲ្យនាំខ្លួននោះទេ ហើយការចេញដីកានេះជាសិទ្ធិអំណាចផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិគ្មានសិទ្ធិអ្វី ក្នុងការឆ្លើយតបទៅនឹងសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននោះទេ[22]។ ចំពោះភាពអាចទទួលយកបាននៃសំណើរបស់ខ្លួន មេធាវីការពារក្តីបានលើកឡើងថា សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានសេរីភាព នឹងត្រូវបានរំលោភ ប្រសិនបើគាត់ត្រូវបានឃុំខ្លួន មុនពេលអង្គបុរេជំនុំជម្រះសម្រេចលើសុពលភាពនៃដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍ ដោយផ្អែកលើវិធាន ២១ ឬដោយអនុវត្តយុត្តាធិការជាប់មកជាមួយរបស់ខ្លួន[23]។ មេធាវីការពារក្តីបានលើកឡើងថា ទោះបីជាសហចៅក្រមស៊ើបអង្កេតអាចមានសមត្ថកិច្ច ក្នុងការពិចារណាលើសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនក៏ដោយ ក៏វាគ្មានប្រយោជន៍អ្វីក្នុងការដាក់សំណើនេះ នៅចំពោះមុខសហ

[17] ចម្លើយតប កថាខណ្ឌ ១៤-១៥។

[18] ចម្លើយតប កថាខណ្ឌ ១៨។

[19] ចម្លើយតប កថាខណ្ឌ ១៩។

[20] ចម្លើយតប កថាខណ្ឌ ២០។

[21] ចម្លើយតប កថាខណ្ឌ ២០។

[22] សារណាតបទៅនឹងចម្លើយតប កថាខណ្ឌ ១-១១។

[23] សារណាតបទៅនឹងចម្លើយតប ១៤។

ចៅក្រមស៊ើបអង្កេតនោះឡើយ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើមិនដឹងមិនឮចំពោះវត្តមាននៃបណ្តឹងឧទ្ធរណ៍ ហើយបែរជាចេញដីកាបង្គាប់ឲ្យនាំខ្លួនទៅវិញ។ ដូច្នេះ មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះដែលអាចធានាបាននូវការគោរពសិទ្ធិរបស់ មាស មុត[24]។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីបានលើកឡើងថា យុត្តាធិការជាប់មកជាមួយរបស់អង្គបុរេជំនុំជម្រះមិនកម្រិតត្រឹមបញ្ហារណបទៅនឹងយុត្តាធិការចម្បង ដូចការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ គឺលាតសន្ធឹងដល់បញ្ហាបន្ទាប់បន្សំទាំងអស់ពាក់ព័ន្ធនឹងយុត្តាធិការចម្បងរបស់ អ.វ.ត.ក[25]។ ក្នុងន័យនេះ មេធាវីការពារក្តីបានអះអាងថា អង្គបុរេជំនុំជម្រះមានកំហុសក្នុងការបកស្រាយសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ក្នុងរឿងក្តី *El Sayed* ជាសាលដីកាដែលអង្គបុរេជំនុំជម្រះបានយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់អំពីយុត្តាធិការជាប់មកជាមួយរបស់ខ្លួន[26]។ ចំពោះសារធាតុ មេធាវីការពារក្តីបានអះអាងជាថ្មីម្តងទៀតថា ការឃុំខ្លួន មាស មុត មុនពេលចេញសេចក្តីសម្រេចស្ថាពរស្តីពីនីត្យានុកូលភាពនៃដីកាសម្រេចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ គឺការជាការរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាព។ មេធាវីការពារក្តីក៏បានអះអាងផងដែរថា មិនមានមូលហេតុអ្វីត្រូវឃុំខ្លួន មាស មុត នោះឡើយ ពីព្រោះគាត់មិនបានរត់គេចនោះទេ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងនគរបាលយុត្តិធម៌ស្គាល់ទីលំនៅរបស់គាត់[27]។

## III- ការបញ្ចេញយោបល់ និងសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍

១១. ទោះបើមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រភាគច្រើនចំនួនបួនសំឡេងតាមការតម្រូវ ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ។ ដោយពិចារណាថា វិធានផ្ទៃក្នុង ៧៧ (១៤) ចែងថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំ

---

[24] សារណាតបទៅនឹងចម្លើយតប កថាខណ្ឌ ១៦។

[25] សារណាតបទៅនឹងចម្លើយតប កថាខណ្ឌ ១៧-១៩។

[26] សារណាតបទៅនឹងចម្លើយតប កថាខណ្ឌ ១៨-១៩ យោងទៅរករឿងក្តី *El Sayed* សំណុំរឿងលេខ C[illegible] សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេត ស្តីពីយុត្តាធិការ និងលក្ខណៈស[illegible] តុលាការ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ៤៥ (“សាលដីកា El Sayed”)។

[27] សារណាតបទៅនឹងចម្លើយតប កថាខណ្ឌ ២៥-៣២។

ជម្រះត្រូវមានសំអាងហេតុ យោបល់សមាជិកម្នាក់ៗរបស់អង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់ជាមួយនឹងសេចក្តីពិចារណាទាំងនេះ។

១២. ដោយហេតុថា អង្គបុរេជំនុំជម្រះមិនអាចសម្រេចលើបណ្តឹងឧទ្ធរណ៍នេះបាន វិធានផ្ទៃក្នុង ៧៧ (១៣) ចែងថា ដីកាដែលរងការជំទាស់ត្រូវបានតម្កល់។

## IV- ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ÷**

**ប្រកាសជាឯកច្ឆន្ទថា** អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រជាវិជ្ឈមានពីចៅក្រមបួនរូប យ៉ាងតិចក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ។

អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្តឹងតវ៉ាទេ។

**រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Steven J. BWANA** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី បង្ហាញយោបល់របស់ពួកគាត់ពាក់ព័ន្ធនឹងចំណុចផ្សេងៗនៃសំណើសុំ ដោយភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនេះ។

ចៅក្រម Oliver BEAVALLET ចៅក្រម Steven J.BWANA បង្ហាញយោបល់របស់ពួកគាត់ពាក់ព័ន្ធនឹងចំណុចផ្សេងៗនៃសំណើសុំ ដោយភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនេះ។

01148490



# យោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី

## ក. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចេញដីកាបង្គាប់ឱ្យនាំខ្លួន ដើម្បី "នាំខ្លួនលោក មាស មុត មកបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ"[28]។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បានចេញចម្លើយតបទៅនឹងសំណើរបស់ មាស មុត សុំមោឃភាពដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដោយបានថ្លែងថា សំណើនេះនៅពេលឥឡូវនេះ ត្រូវបានចាត់ទុកថា មោឃៈហើយ ព្រោះគាត់បានចេញ "ដីកាបង្គាប់ឱ្យនាំខ្លួនថ្មីមួយនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដែលជំនួសដីកាបង្គាប់ឱ្យនាំខ្លួនចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤[29]។

២. នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៥ សហមេធាវីការពារក្តី មាស មុត ដាក់សំណើបន្ទាន់ សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ[30]។

៣. នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិដាក់ចម្លើយតបទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹង

[28] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ (ឯកសារលេខ៖ C2)។

[29] សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ, កថាខណ្ឌទី ៧ (ឯកសារលេខ៖ C2/1)។

[30] សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ (ឯកសារលេខ៖ C2/1)។

ឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ[31]។

៤. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ មាស មុត ដាក់ចម្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ ដែលបានដាក់នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៥[32]។

## ខ.ភាពអាចឧទ្ទួលយកបាន

៥. នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៥ សហមេធាវីការពារក្តី មាស មុត ដាក់សំណើបន្ទាន់ សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ដោយបានលើកនូវទឡ្ហីករណ៍ថា "អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចសម្រេចទៅលើសំណើនេះ អនុលោមតាមការបកស្រាយទូលាយនៃវិធាន ២១ ដោយសារសេចក្តីសម្រេចមួយលើបញ្ហានេះ គឺចាំបាច់ដើម្បីធានាបាននូវភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅក្នុងការស៊ើបសួរ[33]។

---

[31] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ (ឯកសារលេខ៖ C2/2)។

[32] ចម្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ (ឯកសារលេខ៖ C2/3)។

[33] សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ, កថាខណ្ឌទី ៨ (ឯកសារលេខ៖ C2/1)។

៦. ទោះបីសំណើនេះ មិនត្រូវបានអនុញ្ញាតិឱ្យលោក មាស មុត មានសិទ្ធិប្តឹងអនុលោមតាមវិធាន ៧៤ កថាខណ្ឌទី៣ នៃវិធានផ្ទៃក្នុងក៏ដោយ ប៉ុន្តែអង្គបុរេជំនុំជម្រះ ក៏ធ្លាប់បានទទួលយកបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយពិចារណាលើ "ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ២១ (១)(ក) នៃវិធានផ្ទៃក្នុង"[34] កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០។ ហេតុដូច្នេះ ចៅក្រមជាតិ (អ.ប.ជ) នឹងធ្វើការពិចារណា ថាតើសំណើនេះ អាចទទួលយកអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងដែរទេ។

៧. ដីកាបង្គាប់ឱ្យនាំខ្លួន ជាវិធានការបង្ខំដោយប្រើកម្លាំងមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីនាំខ្លួន មាស មុត មកចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ ពុំមាននាំមកចំពោះមុខសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់ទេ។

៨. វិធានការនេះ ក្នុងសង្គមកម្ពុជាចាត់ទុកថា ជាការអាម៉ាស់យ៉ាងខ្លាំង ប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយសសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់ មាស មុត ដែលមិនអាចធ្វើបដិទានឡើងវិញបានឡើយ។

៩. បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ[35] អង្គបុរេជំនុំជម្រះមិនទាន់បានសម្រេចនៅឡើយ។

១០. សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ គឺជាប្រភេទសំណើបណ្តោះអាសន្នតែប៉ុណ្ណោះ។

១១. សំណើនេះ ពុំបង្កើតបានជាឧបសគ្គដល់ដំណើរការដោះស្រាយលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ឡើយ។

១២. អាស្រ័យហេតុនេះ អន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ជាការចាំបាច់ដើម្បីរារាំងមិនឱ្យមានព្យសនកម្មដែលមិនអាចជួសជុលបានដូចខាងលើ។

---

[34] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០, កថាខណ្ឌទី១៤ (អ.ប.ជ ឯកសារលេខ៖ D246/2/6)។

[35] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ (ឯកសារលេខ៖ ៖ D128/1/3)។

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៣)

ឯកសារ C2/4

## ហេតុដូច្នេះ ចៅក្រមជាតិសម្រេច

**ទទួល** សំណើ។

**ផ្អាកការអនុវត្ត** ដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ ដោយកំបាំងមុខ។

**ភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥**

**ប្រធាន ប្រាក់ គឹមសាន** **ចៅក្រម ន័យ ថុល** **ចៅក្រម ហួត វុទ្ធី**

## យោបល់របស់ចៅក្រម Olivier Beauvallet និងចៅក្រម Steven J. Bwana

### ក.ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឲ្យនាំខ្លួន មាស មុត មកចូលរួមសវនាការពាក់ព័ន្ធការឃុំខ្លួនបណ្តោះអាសន្នតាមវិធាន៦៣ នៃវិធានផ្ទៃក្នុង[36]។

2. នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនដោយស្នើសុំអង្គបុរេជំនុំជម្រះ បង្គាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឲ្យផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន[37]។ មេធាវីការពារក្តីបានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួននៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥[38]។

3. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ដោយស្នើសុំអង្គបុរេជំនុំជម្រះសម្រេចថាសំណើរបស់មេធាវីការពារក្តីមិនអាចឲ្យទទួលយកបាន និងជាសំណើពុំមានលក្ខណៈត្រឹមត្រូវទោះស្ថិតក្នុងករណីណាក៏ដោយ[39]។

4. នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ការឆ្លើយតបរបស់ខ្លួន ដោយស្នើសុំអង្គបុរេជំនុំជម្រះសម្រេចថាចម្លើយតបរបស់សហព្រះរាជអាជ្ញា គ្មានភាពអាចឲ្យទទួលយកបាន

---

[36] ដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2។

[37] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន, សន្និដ្ឋាន។

[38] បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ D128/1/3។

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ*, ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥, ឯកសារ C2/2 ។

*សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន*

និងលុបចោលពីសំណុំរឿង ហើយស្នើសុំអង្គបុរេជំនុំជម្រះទទួលយកសំណើរបស់ខ្លួនសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[40]។

## ខ.ភាពអាចទទួលយកបាន

### I-ភាពអាចទទួលយកបាននៃចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

5. យើងពិចារណាឃើញថាយើងគួរបដិសេធអំណះអំណាងរបស់មេធាវីការពារក្តី ដែលថាសហព្រះរាជអាជ្ញាអន្តរជាតិពុំមានចំណាប់អារម្មណ៍គ្រប់គ្រាន់ ដើម្បីឆ្លើយតបសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន[41]។ ដោយហេតុថាការិយាល័យសហព្រះរាជអាជ្ញា ទទួលបន្ទុករៀបចំការចោទប្រកាន់ យើងគួរយល់បានថាសហព្រះរាជអាជ្ញាមានសិទ្ធិធ្វើអន្តរាគមន៍លើបញ្ហានានាទាក់ទងនឹងការបំពេញកិច្ចស៊ើបសួរ រួមទាំងបញ្ហាពាក់ព័ន្ធការចាប់ខ្លួនជនត្រូវចោទផងដែរ។ ជាងនេះទៀត វិធាន ៧៤(២) នៃវិធានផ្ទៃក្នុងចែងថាសហព្រះរាជអាជ្ញាអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងគ្រប់ដីការបស់សហចៅក្រមស៊ើបអង្កេត។ ដូចគ្នានេះ សហព្រះរាជអាជ្ញាអាចធ្វើការឆ្លើយតបសំណើ ឬបណ្តឹងឧទ្ធរណ៍របស់ភាគី ដែលនេះជាមូលហេតុដែលមេធាវីការពារក្តីដាក់ការិយាល័យសហព្រះរាជអាជ្ញាបញ្ចូលទៅក្នុងបញ្ជីចែកចាយសំណើរបស់ខ្លួនសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន។

6. ហេតុដូចនេះ យើងបដិសេធសំណើរបស់មេធាវីការពារក្តីដែលស្នើសុំឱ្យអង្គបុរេជំនុំជម្រះសម្រេចថាចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពុំអាចឱ្យទទួលយកបាន និងលុបចោលចម្លើយតបនេះពីសំណុំរឿង។

### II- ភាពអាចទទួលយកបាននៃសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន

#### ក.ច្បាប់ជាធរមាន

[40] ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលតបទៅនឹងសំណើបន្ទាន់របស់ [illegible] សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើប[illegible] ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែល[illegible] មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* , ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2/3។

[41] ការឆ្លើយតប កថាខណ្ឌ ១-១១។

7. វិធាន៧៧(១១)នៃវិធានផ្ទៃក្នុងចែងថា៖ "ដោយរង់ចាំលទ្ធផលនៃនីតិវិធីរបស់អង្គបុរេជំនុំជម្រះក្រោមវិធាននេះនិងលើកលែងតែអង្គបុរេជំនុំជម្រះបង្គាប់ផ្សេងពីនេះ សហចៅក្រមស៊ើបអង្កេតអាចបន្តការស៊ើបសួររបស់ខ្លួននៅពេលណាដែលអាចធ្វើទៅបាន"។ មាត្រា២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏ចែងដូច្នេះដែរ[42] រួមទាំងវិធាននីតិវិធីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានាផង[43]។ ហេតុនេះបណ្ដឹងឧទ្ធរណ៍ពុំមានអានុភាពផ្អាកកិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្តទៅបានឡើយ លើកលែងតែអង្គជំនុំជម្រះចេញសេចក្ដីសម្រេចបង្គាប់មិនឱ្យអនុវត្តដីកានេះ ឬមានបទបញ្ញត្តិច្បាប់ចែងជាក់លាក់ឱ្យមានការផ្អាកជាស្វ័យប្រវត្ត[44]។

8. កាលពីពេលមុន ដោយសារគ្មានចែងនៅក្នុងបទបញ្ញត្តិពាក់ព័ន្ធក្នុងវិធានផ្ទៃក្នុង, ច្បាប់ អ.វ.ត.ក, និងច្បាប់កម្ពុជា អង្គបុរេជំនុំជម្រះបានសម្រេចថាអង្គបុរេជំនុំជម្រះអាចអនុវត្ត "យុត្តាធិការឥស្សរចិត្ត" របស់ខ្លួនដើម្បី បង្គាប់ឱ្យផ្អាកការអនុវត្តដីការបស់សហចៅក្រមស៊ើបអង្កេត ដើម្បីធានាបានអត្ថន័យនៃសិទ្ធិប្ដឹងឧទ្ធរណ៍ឬដើម្បីរក្សាបានភាពត្រឹមត្រូវនៃដំណើរការនីតិវិធីលើបណ្ដឹងឧទ្ធរណ៍[45]។

---

[42]មាត្រា ២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ចំពោះដីកាណាមួយក្រៅពីដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរអាចបន្តការស៊ើបសួររបស់ខ្លួនបាន លើកលែងតែមានសេចក្ដីសម្រេចផ្ទុយរបស់ប្រធានសភាស៊ើបសួរ។ សេចក្ដីសម្រេចនេះមិនអាចតវ៉ាបានឡើយ"។

[43] នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តុលាការពិសេសសម្រាប់លីបង់ និងតុលាការពិសេសសម្រាប់សៀរ៉ាលីអូន (SCSL) បណ្ដឹងឧទ្ធរណ៍ពុំមានអានុភាពផ្អាកកិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្តទៅបានឡើយ លើកលែងតែអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ឬអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចផ្ទុយដោយយោងទៅលើកាលៈទេសៈ (សូមមើលមាត្រា ៨២(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម, វិធាន ១២៦ (ច) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងនៅតុលាការពិសេសសម្រាប់លីបង់ និងមាត្រា ៧២(ជ) និងមាត្រា ៧៣(ក) និង(ខ) នៃវិធានស្ដីពីនីតិវិធី និងភស្តុតាងនៅតុលាការពិសេសសម្រាប់សៀរ៉ាលីអូន)។

[44] សេចក្ដីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេចឱ្យតែងតាំងមេធាវីបណ្ដោះអាសន្នសម្រាប់លោក មាស មុត, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤, ឯកសារ D56/19/14, កថាខណ្ឌ ១៤ ("សេចក្ដីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤")។

[45] ដីកាសម្រេចការព្យួរការអនុវត្ត "ដីកាសម្រេចស្ដីពីសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣", ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ D14/1/2, សេចក្ដីសម្រេចលើសំណើសុំឱ្យមានវិធានការការពារបណ្ដោះអាសន្ន, ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D56/19/8, កថាខណ្ឌ ១៥, សេចក្ដីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១៦, សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៩), សេចក្ដីសម្រេចលើសំណើបន្ទាន់សុំផ្អាកការអនុវត្តដីកាកោះឱ្យបង្ហាញខ្លួនបឋម ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤, ឯកសារ A122/6.1/3 ("សេចក្ដីសម្រេចលើសំណើសុំផ្អាកការអនុវត្តដីកាកោះ, ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ *សេចក្ដីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន*

បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថាដើម្បីឱ្យសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំផ្អាកការបំពេញកិច្ចដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានជំទាស់ ឬការអនុវត្តដីកាដែលម្ចាស់បណ្តឹងឧទ្ធរណ៍បាននជំទាស់ មានប្រសិទ្ធភាព លុះត្រាតែមានភស្តុតាងថាការបំពេញកិច្ច ឬការអនុវត្តដីកានោះ "នឹងនាំឱ្យមានផលវិបាកដោយផ្ទាល់ទៅលើកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ដែលខ្លួនបានទទួល"[46] និងត្រូវតែបំពេញលក្ខខណ្ឌចំនួនបីផងដែរដូចជា៖ "ក. មានហេតុផលត្រឹមត្រូវសម្រាប់ការផ្អាកដែលបានស្នើសុំ, ខ.ការផ្អាកដែលបានស្នើសុំត្រូវមានរយៈពេលសមស្រប, គ.បណ្តឹងឧទ្ធរណ៍មានលទ្ធភាពសមស្របក្នុងការទទួលជោគជ័យលើផ្នែកអង្គសេចក្តី"[47]។ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថាខ្លួនគ្មានយុត្តាធិការដើម្បីបង្គាប់ឱ្យផ្អាកការអនុវត្តដីការបស់សហចៅក្រមស៊ើបអង្កេតឡើយ កាលណាលក្ខខណ្ឌទីមួយពុំត្រូវបានបំពេញ[48]។ ហេតុដូចនេះអង្គបុរេជំនុំជម្រះបានសម្រេចថា សំណើសុំផ្អាកការអនុវត្តដីកាណាមួយដែលការអនុវត្តដីកានោះពុំប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ដែលខ្លួនបានទទួល ពុំស្ថិតក្រោមសមត្ថកិច្ចយុត្តាធិការរបស់ខ្លួនឡើយ។ ហេតុដូច្នេះសំណើនោះគឺពុំអាចឱ្យទទួលយកបានឡើយ[49]។

9. វិធាន ២១ នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកពាក់ព័ន្ធដូចខាងក្រោមនេះ៖

**វិធាន ២១. គោលការណ៍ជាសារវន្ត**

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនដែលត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ច

២០១៤") កថាខណ្ឌ ៦, *សូមមើលផងដែរ* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (២៦), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ,អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ E284/2/1/2, កថាខណ្ឌ ១២។

[46] សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១៦។

[47] សេចក្តីសម្រេចលើសំណើសុំផ្អាកការអនុវត្តដីកាកោះ, ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤") កថាខណ្ឌ ១០, *ដោយ[illegible] លើ* តុលាការពិសេសសម្រាប់លីបង់, សំណុំរឿង CH/AC/2011/01, ដីកាសម្រេចលើសំណើបន្ទាន់របស់រដ្ឋអា[illegible] រង់ចាំបណ្តឹងឧទ្ធរណ៍, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៨ និងកថាខណ្ឌ ១១។

[48] សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១៦។

[49] សេចក្តីសម្រេចលើសំណើសុំឱ្យផ្អាកការអនុវត្តដីកាសម្រេច ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១៨-១[illegible] *សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន*

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

ភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ នីតិវិធីត្រូវធានាឱ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

[...]

២. វិធានការចាប់បង្ខំទាំងឡាយណាចំពោះបុគ្គលណាម្នាក់ ត្រូវធ្វើឡើងដោយ ឬស្ថិតនៅក្រោមការត្រួតពិនិត្យដោយយកចិត្តទុកដាក់ពីអាជ្ញាធរ មានសមត្ថកិច្ច របស់អង្គជំនុំជម្រះវិសាមញ្ញ។ វិធានការនេះត្រូវតែកម្រិតតឹងរ៉ឹងបំផុតសម្រាប់តែ តម្រូវការនៃដំណើរការនីតិវិធីដោយសមាមាត្រទៅនឹងកម្រិតធ្ងន់ធ្ងរនៃបទល្មើស ដែលចោទប្រកាន់ និងដោយគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិឱ្យបានពេញលេញ។

អង្គបុរេជំនុំជម្រះបានសម្រេចពីពេលមុនថាគោលការណ៍ជាសារវន្តដូចមានចែងក្នុងវិធាននេះ ដែល អ.វ.ត.ក ត្រូវអនុវត្តដើម្បីការជំនុំជម្រះប្រកបដោយយុត្តិធម៌អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[50] មាត្រា ៣៥ ថ្មីនៃច្បាប់ អ.វ.ត.ក[51] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[52] អាចធានាបានថាគោលការណ៍នេះបកស្រាយក្នុងន័យទូលាយអំពីសិទ្ធិប្តឹងឧទ្ធរណ៍ដើម្បីធានាបានថាកិច្ច

[50] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

[51] មាត្រា ៣៥ ថ្មី ច្បាប់ អ.វ.ត.ក។

[52] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (សំណុំរឿង ០០២) ([illegible]) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[illegible] សំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃ[illegible] ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ A371/2/12 កថាខណ្ឌ ១៣-១៨, កថាខណ្ឌ ២៧។

ដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ[53]។ ក្នុងករណីកម្រ ដែលអង្គហេតុណាមួយនៃសំណុំរឿង លើកឡើងអំពីបញ្ហាសិទ្ធិជាសារវន្ត ឬបញ្ហាធ្ងន់ធ្ងរនៃភាពត្រឹមត្រូវផ្នែកនីតិវិធី អង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍តាមវិធាន ២១[54] ឬធ្វើការបកស្រាយក្នុងន័យទូលាយអំពីបញ្ញត្តិជាក់លាក់នៃវិធានផ្ទៃក្នុងដែលផ្តល់យុត្តាធិការដល់អង្គបុរេជំនុំជម្រះ[55]។ អង្គបុរេជំនុំជម្រះរមែងបានរម្លឹកថាវិធាន២១នៃវិធានផ្ទៃក្នុង ពុំបើកផ្លូវប្តឹងឧទ្ធរណ៍ឡើយទោះបីក្នុងករណីដែលបណ្តឹងឧទ្ធរណ៍លើកអំពីបញ្ហាទាក់ទងការជំនុំជម្រះដោយយុត្តិធម៌ក៏ដោយ។ នៅក្នុងករណីពិសេស ដើម្បីឱ្យអង្គបុរេជំនុំជម្រះពិនិត្យបណ្តឹងឧទ្ធរណ៍តាមវិធាន២១ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវតែបង្ហាញថាករណីនោះពុំមានចែងក្នុងវិធានជាធរមាននានា ហើយកាលៈទេសៈពិសេសនៃសំណុំរឿងតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើអន្តរាគមន៍ដើម្បីជៀសវាងការប៉ះពាល់ *ដែលមិនអាចផ្សះផ្សាបាន* ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីស៊ើបសួរ ឬសិទ្ធិជាសារវន្តរបស់ម្ចាស់បណ្តឹង

---

[53] *សូមមើល ឧទាហរណ៍ ៖* សំណុំរឿង ០០២ (អ.ប.ជ ១១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងដីកាបង្គាប់ស្តីពីសិទ្ធិបកប្រែឯកសារ និងកាតព្វកិច្ចរបស់ភាគី, ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩, ឯកសារ A190/1/20, កថាខណ្ឌ ៣៦, សំណុំរឿង ០០២ (អ.ប.ជ ៧១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារ D390/1/2/4 កថាខណ្ឌ ១៣ (“សាលដីកាលើចម្លើយតបរបស់ អៀង សារី”), សំណុំរឿង ០០២ (អ.ប.ជ ១៤) សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីស្តីពីកំហុសនៃការបកប្រែឯកសារ, ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០, ឯកសារ លេខ ២, កថាខណ្ឌ ៣ (“សេចក្តីសម្រេចស្តីពីកំហុសនៃការបកប្រែឯកសារ”), សំណុំរឿង ០០២ (អ.ប.ជ ៧៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១, ឯកសារ D427/1/30, កថាខណ្ឌ ៤៩។

[54] *សូមមើល ជាឧទាហរណ៍៖* សំណុំរឿង ០០២ (អ.ប.ជ ៤២), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ, ឯកសារ (D264/1), ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០, ឯកសារ D264/2/6, កថាខណ្ឌ ១៣-១៤, សេចក្តីសម្រេចលើចម្លើយតបរបស់ អៀង សារី, កថាខណ្ឌ ១៣, សេចក្តីសម្រេចស្តីពីកំហុសនៃការបកប្រែឯកសារ, កថាខណ្ឌ ២-៦។

[55] *សូមមើលឧទាហរណ៍៖* សំណុំរឿង ០០២ (អ.ប.ជ០៥), សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីសិទ្ធិជួបសួរសុខទុក្ខ, ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៨, ឯកសារ A104/II/4, កថាខណ្ឌ ១០។ *សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន*

ឧទ្ធរណ៍[56]។

## ខ. ការសម្រេចស្តីពីភាពអាចទទួលយកបាននៃសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន

10. យើងកត់សម្គាល់ឃើញមេធាវីការពារក្តីពុំបានអះអាងថា សំណើរបស់ខ្លួនសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ស្ថិតក្រោមយុត្តាធិការឥស្សរចិត្តរបស់អង្គជំនុំជម្រះឡើយ ប៉ុន្តែជំនួសមកវិញ (i) ស្នើសុំអង្គបុរេជំនុំជម្រះពង្រីកវិសាលភាពនៃយុត្តាធិការឥស្សរចិត្តរបស់បុរេជំនុំជម្រះ ដើម្បីគ្របដណ្តប់លើបញ្ហានានាដែលស្ថិតក្រោមយុត្តាធិការបឋម*របស់ អ.វ.ត.ក*[57] ទៅវិញ ឬ (ii) ស្នើសុំអង្គបុរេជំនុំជម្រះទទួលយកសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដោយអនុលោមតាមវិធាន ២១[58]។ អង្គបុរេជំនុំជម្រះសូមយកសំណើទាំងពីរចំណុចនេះមកធ្វើការពិចារណាម្តងមួយដូចខាងក្រោម។

### i) យុត្តាធិការឥស្សរចិត្តរបស់អង្គបុរេជំនុំជម្រះ

11. យើងកត់សម្គាល់ឃើញភាពខុសគ្នាជាសារវន្តមួយរវាងយុត្តាធិការឥស្សរចិត្ត*របស់ អ.វ.ត.ក* និងយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ក្នុងនាមជាអង្គជំនុំជម្រះទទួលបន្ទុកចាត់ការបណ្តឹងឧទ្ធរណ៍នៅក្នុងប្រព័ន្ធយុត្តិធម៌នៅ អ.វ.ត.ក។ ជាបឋម ប្រសិនបើអង្គបុរេជំនុំជម្រះពិចារណាអំពីបញ្ហាបន្ទាប់បន្សំដែលកើតមកអំពីយុត្តាធិការរបស់ អ.វ.ត.ក ដូចដែលមេធាវីការពារក្តីហាក់ដូចជាកំពុងស្នើសុំឱ្យពិចារណា អង្គបុរេជំនុំជម្រះនឹងដណ្តើមសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេត ក៏ដូចជាប្រហែលជាដណ្តើមសិទ្ធិអំណាចរបស់អង្គជំនុំជម្រះដទៃទៀតដែលស្ថិតនៅក្នុង អ.វ.ត.ក ក៏ថាបាន។ ហេតុនេះដើម្បីឱ្យសារណាដែលធ្វើនៅដំណាក់កាលដំបូង ស្ថិតក្រោមដែនសមត្ថកិច្ចយុត្តាធិការរបស់អង្គបុរេជំនុំជម្រះ ទាល់តែសារណានោះទាក់ទងដោយផ្ទាល់ទៅនឹងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ដែលអង្គបុរេជំនុំជម្រះបានទទួល។

---

[56] *សូមមើល ជាឧទាហរណ៍* សំណុំរឿង ០០៤ (អ.ប.ជ ១៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកា[illegible] បដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី [illegible] ឆ្នាំ ២០១៣ ,ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D208/1/1/2, កថាខណ្ឌ ៨។

[57] ការឆ្លើយតប, កថាខណ្ឌ ១៩។

[58] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន, កថាខណ្ឌ ៨។

12. ការបកស្រាយនេះស៊ីសង្វាក់ទាំងស្រុងជាមួយដីកាសម្រេច *El Sayed* របស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់លីបង់ ដែលអង្គបុរេជំនុំជម្រះធ្លាប់បានលើកមកធ្វើជាសំអាងក្នុងការកំណត់វិសាលភាពយុត្តាធិការឥស្សរចិត្តរបស់ខ្លួន ហើយមេធាវីការពារក្តីតវ៉ាថាអង្គបុរេជំនុំជម្រះត្រូវតែពិចារណាឡើងវិញអំពីការបកស្រាយនេះ។ នៅគ្រាដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់លីបង់បានផ្តល់និយមន័យ "យុត្តាធិការឥស្សរចិត្ត" ថាជា "អំណាចរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ដើម្បីសម្រេចលើបញ្ហាច្បាប់បន្ទាប់បន្សំ ដែលកើតឡើងជាផលវិបាកផ្ទាល់នៃនីតិវិធីដែលតុលាការបានទទួលដោយសារបញ្ហានោះ ស្ថិតក្រោមយុត្តាធិការបឋមរបស់ខ្លួន[59] អង្គជំនុំជម្រះតុលាការកំពូលកំពុងពិនិត្យបណ្តឹងឧទ្ធរណ៍ស្តីពីការសម្រេចរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ ស្តីពីយុត្តាធិការរបស់តុលាការពិសេសសម្រាប់លីបង់លើសំណើរបស់លោក El Sayed។ លើបញ្ហានោះ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ពុំបានពិចារណាថាតើខ្លួនមានយុត្តាធិការដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ដែរឬយ៉ាងណាឡើយ ដោយការសម្រេចលើបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើដាច់ដោយឡែក និងក្នុងលក្ខខណ្ឌផ្សេង[60]។

13. អាស្រ័យហេតុនេះ យើងសម្រេចថាសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មានភាពអាចឱ្យទទួលយកបាន តែត្រង់ផ្នែកដែលការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនអាចប៉ះពាល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ឬប៉ះពាល់ដល់សិទ្ធិប្តឹងឧទ្ធរណ៍ដែលបានការទទួលស្គាល់ប៉ុណ្ណោះ។

14. នៅក្នុងករណីបច្ចុប្បន្ននេះ មេធាវីការពារក្តីពុំបានតវ៉ាថាការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនអាចប៉ះពាល់កិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។ ជំនួសមកវិញ មេធាវីការពារក្តីអះអាងថាប្រសិនបើដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានអនុវត្ត នៅពេលអង្គបុរេជំនុំជម្រះមិនទាន់ធ្វើការសម្រេចអំពីភាពស្របច្បាប់នៃដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការត្រួតពិនិត្យ មាស មុត អាចត្រូវបានឃុំឃាំងដោយផ្អែកលើសេចក្តីសម្រេចមួយដែលពុំមានសុពលភាពគតិយុត្ត[61]។ ដោយហេតុថាសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះ ពុំពាក់ព័ន្ធអំពីការដាក់ មាស មុត

[59] សេចក្តីសម្រេច El Sayed កថាខណ្ឌ ៤៥។

[60] សេចក្តីសម្រេច El Sayed កថាខណ្ឌ ៥៤-៥៥។

[61] សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន, កថាខណ្ឌ ៨-១១។

ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ប៉ុន្តែពាក់ព័ន្ធការឃុំខ្លួន មាស មុត ជាបណ្ដោះអាសន្ន ដែលអង្គបុរេជំនុំជម្រះមិនបានទទួល យើងពិចារណាឃើញថាសំណើនេះមិនស្ថិតក្រោមសមត្ថកិច្ចយុត្តាធិការឥស្សរចិត្តរបស់អង្គបុរេជំនុំជម្រះឡើយ។

ii) **វិធាន ២១ នៃវិធានផ្ទៃក្នុង**

15. ទាក់ទិនទៅនឹងភាពអាចឱ្យទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះតាមវិធាន២១នៃវិធានផ្ទៃក្នុង យើងកត់សម្គាល់ឃើញថាសំណើមួយដែលមានលំដាប់លំដោយត្រឹមត្រូវ ប៉ុន្តែពុំបំពេញលក្ខខណ្ឌតម្រូវនៃភាពអាចឱ្យទទួលយក ក៏យើងមិនអាចប្រើប្រាស់វិធាននេះដើម្បីទទួលយកសំណើបែបនោះបានដែរ។ នៅក្នុងករណីនេះ វិធានគ្របដណ្ដប់លើភាពអាចទទួលយកបាននៃសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានអង្គបុរេជំនុំជម្រះពន្យល់ច្បាស់រួចទៅហើយ ដូច្នេះវិធាន២១នៃវិធានផ្ទៃក្នុងពុំមែនជាជម្រើសមួយទៀតឡើយ។

16. លើសពីនេះ យើងពុំជឿជាក់ឡើយទៅលើទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលថាការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មុនពេលមានសាលដីកាលើបណ្ដឹងឧទ្ធរណ៍ នឹងរំលោភគោលការណ៍ជាសារវ័ន្តដូចមានចែងក្នុងវិធាន២១។ ដូចដែលឈ្មោះរបស់ដីកានេះ [ជាភាសាបារាំង៖mandate d'amerner] បានបញ្ជាក់ ដីកាបង្គាប់ឱ្យនាំខ្លួនមានគោលបំណងនាំខ្លួន មាស មុត មកចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីធ្វើសវនាការមួយដែលនឹងពិនិត្យអំពី *លទ្ធភាព* នៃការឃុំខ្លួនគាត់ជាបណ្ដោះអាសន្នអនុលោមតាមវិធាន ៦៣ នៃវិធានផ្ទៃក្នុង។ ហេតុដូចនេះ នៅក្នុងសវនាការប្រតិបត្តិ មាស មុត នឹងមានសិទ្ធិលើកអំណះអំណាងដែលគាត់យល់ថាសមស្រប នៅពេលមិនទាន់មានសេចក្ដីសម្រេចថាត្រូវឃុំខ្លួនគាត់ជាបណ្ដោះអាសន្នឬយ៉ាងណា។ ហេតុដូច្នេះក្នុងបញ្ហានេះ គោលការណ៍ដូចមានចែងក្នុងវិធាន ២១(២) នៃវិធានផ្ទៃក្នុង និងជាទូទៅ សិទ្ធិរបស់មេធាវីការពារក្ដីត្រូវបានគាំពារយ៉ាងពេញលេញ។ ក្នុងករណីនេះ យើងពុំពិចារណាឃើញថាការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននៅពេលមិនទាន់មានសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យនឹងប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ឬប៉ះពាល់សិទ្ធិទទួលបានសេរីភាពរបស់ មាស មុត ឡើយ។

17. យើងពិចារណាឃើញថាសំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ពុំស្ថិតក្រោមយុត្តាធិការរបស់អង្គបុរេជំនុំជម្រះឡើយ។ ហេតុដូច្នេះសំណើនេះមិនអាចឱ្យអង្គបុរេជំនុំជម្រះទទួលយកបានទេ។

**អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិយល់ឃើញថា ៖**

ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អាចអាចឱ្យទទួលយកបាន។

សំណើសុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មិនអាចទទួលយកបាន។

**ភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៥**

ចៅក្រម Olivier BEAUVALLET ចៅក្រម Steven J. BWANA